# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអប់រំ យុវជន និងកីឡា




# ក្លឹបនិពន្ធ

គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២
សហការជាមួយកម្មវិធីសាលារៀនជំនាន់ថ្មី

ភ្នំពេញ ខែមករា ឆ្នាំ២០២១

# មាតិកា

១. សនិទានភាព ..... 1
២. លទ្ធផលសិក្សា ..... 1
២.១. វត្ថុបំណង ..... 1
២.២ លទ្ធផល ..... 1
៣. សម្ភារៈ ..... 2
៤. ដំណើរការអនុវត្ត ..... 2
៤.១. គោលការណ៍រៀបចំ ..... 2
៤.១.១ ការស្ម័គ្រចិត្ត ..... 2
៤.១.២ ទំហំ ..... 2
៤.១.៣ កម្រិតថ្នាក់គោលដៅ ..... 3
៤.១.៤ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស ..... 3
៤.១.៥ ការបែងចែកភារកិច្ច ..... 4
៤.១.៦ ការកំណត់ផែនការ ..... 4
៤.១.៧ ការកំណត់ធនធាន ..... 5
៤.២. សកម្មភាពស្នើឡើង ..... 5
៤.២.១. សំណេរច្នៃប្រឌិត (Creative Writing) ..... 5
៤.២.២. កំណាព្យ (Poetry) ..... 6
៤.២.៣. ទិនានុប្បវត្តិ (Journals) ..... 6
៤.២.៤. សំបុត្រ (Letters) ..... 6
៤.២.៥. ការបោះពុម្ព (Publications) ..... 6
៤.២.៦. ការប្រជុំឱ្យតម្លៃស្នាដៃនិពន្ធ ..... 7
៤.២.៧. ដំណើរទស្សនកិច្ចឆ្លុះបញ្ចាំង ..... 7
៤.២.៨. ការទំនាក់ទំនងរោងពុម្ពក្នុងមូលដ្ឋានសម្រាប់បោះពុម្ពអត្ថបទរឿងរបស់សិស្ស ..... 7
៤.៣. ការប្រជុំឆ្លុះបញ្ចាំងដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំ ..... 7
ឧបសម្ព័ន្ធទី ១ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស ..... 8
ឧបសម្ព័ន្ធទី ២. ការបែងចែកភារកិច្ច ..... 9
ឧបសម្ព័ន្ធទី ៣ ការកំណត់ផែនការ ..... 10
ឧបសម្ព័ន្ធទី ៤៖ ការកំណត់ធនធាន ..... 11
ឧបសម្ព័ន្ធទី ៥៖ សកម្មភាពសំណេរបែបច្នៃប្រឌិត ..... 12
ឧបសម្ព័ន្ធទី ៦៖ ការតែងកំណាព្យ ..... 16
ឧបសម្ព័ន្ធទី៧៖ សៀវភៅកំណត់ត្រាប្រចាំថ្ងៃ ..... 23
ឧបសម្ព័ន្ធទី ៨៖ ការអានសំណួរពិភាក្សាយល់ដឹង ..... 24

## ១. សនិទានភាព

ឯកសារនេះរៀបចំឡើងដើម្បីជួយសិស្សមធ្យមសិក្សាក្នុងការរៀបចំក្លឹប និងផ្តល់ឱកាសសម្រាប់ពួកគេចូលរួមសកម្មភាពក្លឹបនិពន្ធប្រកបដោយភាពច្នៃប្រឌិត។ ឱកាសទាំងអស់នេះមានបំណងផ្តល់នូវបរិយាកាសសិក្សាដល់សិស្ស ដែលមិនទាន់មានការអភិវឌ្ឍផ្នែកបំណិនសំណេរល្អនៅឡើយ។ បញ្ហាទាំងនោះរួមមានកង្វះខាតគំរូសំណេរល្អៗ អ្នកនិពន្ធគំរូ និងបច្ចេកទេសសំណេរដែលផ្តោតលើខ្លឹមសារជាងផ្តោតតែទៅលើអក្ខរាវិរុទ្ធ និងវេយ្យាករណ៍តែមួយផ្នែក។ គេជឿជាក់ថាបរិយាកាសអប់រំនៅក្នុងសាលារៀនបែបនេះ មិនសូវធ្វើឱ្យសិស្សមានការចាប់អារម្មណ៍លើការអភិវឌ្ឍបំណិនសរសេរទេ។ *ការបង្កើតក្លឹបនិពន្ធគឺជាវិធីមួយឆ្លើយតបនឹងបញ្ហាខាងលើទាំងនេះ*។ ហេតុនេះហើយ ក្លឹបនេះមានគោលបំណងជួយលើកទឹកចិត្តសិស្សឱ្យមានការសរសេរក្នុងបរិយាកាសវិជ្ជមាន។ គេគួរតែលើកទឹកចិត្ត និងជំរុញសមាជិកក្លឹបទាំងអស់ឱ្យចេះពិភាក្សាពីសំណេររបស់ពួកគេប្រកបដោយការស្ថាបនា ដែលខុសពីការវាយតម្លៃតាមទម្លាប់ធម្មតានៅក្នុងថ្នាក់រៀន។ ការផ្តល់ព័ត៌មានត្រឡប់គួរធ្វើឡើងដោយមិត្តភក្តិ និងគ្រូដឹកនាំក្លឹប ដែលចុងក្រោយនឹងជួយឱ្យសិស្សចេះស្វ័យវាយតម្លៃដោយខ្លួនឯង។ សកម្មភាពក្លឹបសិក្សាក៏នឹងជួយគាំទ្រ ផ្តល់តម្លៃដល់សំណេររបស់សិស្សតាមរយៈការបោះពុម្ពស្នាដៃសំណេរ ការរៀបចំកម្មវិធីប្រកួតប្រជែង និងការស្វែងរកការបោះពុម្ពតាមសារព័ត៌មាន និងទិនានុប្បវត្តិ។ ជាចុងក្រោយ ក្លឹបនេះនឹងបង្កបរិយាកាសសប្បាយរីករាយដល់សិស្សក្នុងការនិពន្ធនូវអ្វីដែលគួរឱ្យចាប់អារម្មណ៍ដូចជា រឿងប្រលោមលោកថ្មីៗ ការពិភាក្សាឱ្យតម្លៃអំណានជាមួយមិត្តភក្តិ និងមានឱកាសជួបជាមួយអ្នកនិពន្ធនៅក្នុងប្រទេសកម្ពុជា។ គេសង្ឃឹមថា ឱកាសរៀនសូត្របន្ថែមទាំងនេះនឹងធ្វើឱ្យការរៀនកាន់តែគួរឱ្យចាប់អារម្មណ៍ស្របតាមបញ្ញត្តិទូទៅនៃកម្មវិធីសាលាកុមារមេត្រី។

## ២. លទ្ធផលសិក្សា

### ២.១. វត្ថុបំណង

តាមរយៈការពិភាក្សាបញ្ហាពាក់ព័ន្ធខាងលើ សកម្មភាពក្លឹបនិពន្ធមានវត្ថុបំណងដូចខាងក្រោម៖

- សិស្សមានឱកាសបន្ថែមដើម្បីអភិវឌ្ឍបំណិនសរសេរក្រោមបរិយាកាសបែបស្ថាបនា ដោយគ្មានការស្តីបន្ទោស និងគំរាមកំហែង។
- គ្រូដឹកនាំក្លឹបអាចប្រើឯកសារនេះដើម្បីជួយសិស្សឱ្យចេះរៀបចំសកម្មភាព ដែលផ្តល់បរិយាកាសឱ្យពួកគេអភិវឌ្ឍបំណិនសរសេរ។

### ២.២ លទ្ធផល

ដើម្បីសម្រេចនូវវត្ថុបំណងខាងលើ កម្មវិធីត្រូវអនុវត្តតាមសកម្មភាពដូចខាងក្រោមៈ

- អភិវឌ្ឍយន្តការដែលនឹងជំរុញឱ្យសិស្សពង្រឹងនូវសមត្ថភាពសរសេររបស់ពួកគេ។
- បង្កើនឱកាសសម្រាប់សិស្សក្នុងការឱ្យតម្លៃអំណានរបស់ពួកគេ។
- ជួយសិស្សឱ្យចេះពិភាក្សាពីសំណេរ ការបង្ហាញមតិយោបល់ បង្កើតនូវភាពច្នៃប្រឌិតដែលឆ្ពោះទៅរកការបង្កើនចំណេះដឹងផ្ទាល់ខ្លួន។

## ៣. សម្ភារៈ

សម្ភារៈដែលបានរៀបរាប់នៅខាងក្រោមមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ វាអាស្រ័យលើសកម្មភាពដែលសិស្សអនុវត្តក្លឹប។

- ធនធានឯកសារ (ឧ. រឿងប្រលោមលោកទំនើបៗ ការណែនាំការសរសេរ ការនិពន្ធកំណាព្យ ។ល។)
- សម្ភារៈរៀនសូត្រ ប៊ិក សៀវភៅកំណត់ត្រាប្រចាំថ្ងៃ/សៀវភៅសរសេរ
- ថវិកាក្លឹបចំនួន ៦០០,០០០ រៀល ទៅ ៨០០,០០០ រៀល ដើម្បីសម្របសម្រួលសកម្មភាពដែលបានជ្រើសរើស (ឧ. ទស្សនកិច្ចមូលដ្ឋាន ការថតចម្លងឯកសារឱ្យសិស្ស។ល។)
- ប្រាក់ឧបត្ថម្ភសម្រាប់គ្រូ ប្រសិនបើចាំបាច់។

## ៤. ដំណើរការអនុវត្ត

### ៤.១. គោលការណ៍រៀបចំ

ការបង្កើតក្លឹបនិពន្ធសម្រាប់សិស្ស ត្រូវអនុវត្តតាមគោលការណ៍សំខាន់ៗមួយចំនួន ដែលមានពន្យល់ដូចខាងក្រោម៖

#### ៤.១.១ ការស្ម័គ្រចិត្ត

ការចូលរួមក្នុងក្លឹបនិពន្ធ មិនមែនសម្រាប់សិស្សគ្រប់គ្នានោះទេ ហើយអ្នកសម្របសម្រួលសាលារៀនទាំងអស់ត្រូវយល់ថា មិនមានការបង្ខិតបង្ខំសិស្សឱ្យចូលរួមក្នុងក្លឹបនេះដែរ។ ពួកគេអាចមានចំណាប់អារម្មណ៍លើក្លឹបផ្សេងៗទៀតដែរ ហើយទាំងអស់នេះគួរអនុវត្តតាមបញ្ញត្តិនៃសាលាកុមារមេត្រី។ ឧទាហរណ៍ ការរៀបចំក្លឹបនិពន្ធអាចត្រូវបានធ្វើឡើង នៅពេលតែមួយដែលក្លឹបផ្សេងទៀតកំពុងត្រូវបានបង្កើតឡើង ពោលគឺប្រហែលជាមានគ្រូណាម្នាក់កំពុងតែបង្កើតក្លឹបសម្រាប់មុខវិជ្ជាផ្សេងៗទៀតដែរ ដូចជាក្លឹបប្រវត្តិសាស្ត្រ ឬក្លឹបសិល្បៈ។ សិស្សត្រូវបានអនុញ្ញាតឱ្យជ្រើសរើសដោយខ្លួនឯងនូវប្រភេទមុខវិជ្ជាដែលពួកគេចង់សិក្សាស៊ីជម្រៅ និងសម្រេចថាតើពួកគេមានពេលវេលា និងចំណាប់អារម្មណ៍យ៉ាងណាក្នុងការចូលរួមក្លឹបនេះ។

ស្រដៀងគ្នានេះដែរ លោកគ្រូ អ្នកគ្រូមិនត្រូវបង្ខំចាត់តាំងឱ្យរៀបចំដឹកនាំក្លឹបនេះទេ។ សេចក្ដីពេញចិត្ត និងការចាប់អារម្មណ៍របស់គ្រូចំពោះការនិពន្ធ ជាប្រការចាំបាច់ណាស់ក្នុងការឈានទៅដល់ភាពជោគជ័យរបស់ក្លឹប។ ហើយយើងគួរគិតថាសេចក្ដីពេញចិត្តនោះពិបាកនឹងធានាថាទទួលបាន ប្រសិនបើបង្ខំគ្រូឱ្យអនុវត្តសកម្មភាពនោះ។ ព្រមជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តអាចចំណាយពេលផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធ្វើផែនការសកម្មភាពជាមួយសិស្សដូចជា ការចូលរួមប្រជុំក្រៅម៉ោងសិក្សា និងក្នុងសកម្មភាពទស្សនកិច្ចមូលដ្ឋាន។ សាលារៀនត្រូវពិចារណាលើបែបបទនៃការផ្ដល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ថវិកាសកម្មភាពផ្សេងៗទៀតដូចជា ការបំប៉នសិស្សរៀនយឺត និងកម្មវិធីគេហកិច្ចជាដើម។

#### ៤.១.២ ទំហំ

ក្លឹបនិពន្ធនេះមានភាពងាយស្រួលក្នុងការគ្រប់គ្រង ពេលធ្វើក្នុងសាលារៀនតែមួយ ដោយសារសិស្សនិងគ្រូទាំងអស់ស្ថិតនៅកន្លែងជាមួយគ្នា។ ក្នុងករណីខ្លះសាលារៀនមួយចំនួន ដែលនៅក្បែរគ្នាក្នុងតំបន់គោលដៅក៏អាចចូលរួមក្នុងក្លឹបនិពន្ធនេះបានដែរ។ ក្នុងករណីនោះសាលារៀនមធ្យមសិក្សាធនធាន ដើរតួជាអ្នកសម្របសម្រួល។ ប្រសិនបើមានសាលារៀនមួយចំនួនកំពុងអនុវត្តក្លឹបនិពន្ធ នាយកសាលាទាំងអស់ដែលពាក់ព័ន្ធអាចសម្រេចចិត្តដាក់ធនធានរួមគ្នាធ្វើសកម្មភាពដូចជា ទស្សនកិច្ចសិក្សា ពិព័រណ៍ស្នាដៃសំណេរ។ល។ ការអនុវត្ត

សកម្មភាពរួមគ្នាមានអត្ថប្រយោជន៍មួយចំនួនដូចជា ការធ្វើសកម្មភាពជាន់គ្នាជាពិសេសករណីដំណើរទស្សនកិច្ចសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយការសម្របសម្រួលក្នុងកម្រិតនេះ ពេលខ្លះអាចជួបបញ្ហាប្រឈមមួយចំនួន។ នាយកសាលាដែលពាក់ព័ន្ធគួរពិនិត្យមើលកម្រិតចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបនិពន្ធតាមសាលារៀន ចម្ងាយរវាងសាលារៀន និងការពេញចិត្តរបស់គ្រូដឹកនាំនៅពេលសម្រេចចិត្តថា តើត្រូវរៀបចំក្លឹបរួមគ្នា ឬធ្វើដាច់ដោយឡែកពីគ្នា។ ក្នុងការអនុវត្តសកម្មភាពរួមគ្នា ត្រូវចាត់ចែងថវិកាមួយចំនួនដែលចាំបាច់សម្រាប់ធ្វើដំណើរសម្របសម្រួលកិច្ចប្រជុំអន្តរសាលារៀន។

### ៤.១.៣ កម្រិតថ្នាក់គោលដៅ

ការចូលរួមនៅក្នុងក្លឹបនិពន្ធ គឺជាសកម្មភាពមួយដែលមានភាពល្អប្រសើរ គួរជ្រើសរើសសិស្សដែលមានភាពពេញវ័យ។ នៅពេលសាលាមានបទពិសោធន៍ច្រើនក្នុងការរៀបចំក្លឹបនេះហើយ គ្រូប្រហែលជាអាចធ្វើការសាកល្បងរៀបចំ សកម្មភាពទាំងឡាយដែលសមស្របទៅអាយុរបស់សិស្ស។ ទោះជាយ៉ាងក៏ដោយ ជាជំហានដំបូងគេបានណែនាំថាក្លឹបនិពន្ធ ផ្តោតទៅលើសិស្សថ្នាក់ទី ៨ ឬទី ៩ អាស្រ័យទៅលើលទ្ធភាពរបស់គ្រូដែលចាប់អារម្មណ៍ក្នុងការធ្វើការជាមួយសិស្ស។

### ៤.១.៤ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស

ការសម្រេចចិត្តរបស់សិស្សក្នុងការចូលរួមក្លឹប គួរតែផ្អែកលើការផ្តល់ព័ត៌មានច្បាស់លាស់ជាមុន។ ក្នុងការវាយតម្លៃចំណាប់អារម្មណ៍របស់សិស្សចូលរួមក្នុងក្លឹប ជាដំបូងគ្រូត្រូវផ្តល់នូវព័ត៌មានណែនាំថា តើក្លឹបនេះគឺជាអ្វី។ ការតម្រង់ទិសនេះអាចធ្វើឡើងតាមរយៈការពន្យល់ផ្ទាល់មាត់តាមថ្នាក់ ឬការពន្យល់ជាលាយលក្ខណ៍អក្សរដែលបិទផ្សាយជាសាធារណៈ ឬរៀបចំទាំងពីរក៏បាន។ ចំណុចមួយចំនួនដែលត្រូវលើកឡើងនៅក្នុងការណែនាំគួររួមបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- ***<u>វត្ថុបំណង៖</u>*** ផ្តល់បរិយាកាសជាវិជ្ជមាន និងគ្មានការគំរាមកំហែងចំពោះការអភិវឌ្ឍបំណិនសរសេរ។
- ***<u>សកម្មភាព៖</u>*** ការចុះតាមមូលដ្ឋាន ការសរសេរកំណត់ត្រាប្រចាំថ្ងៃ ការពិភាក្សាក្រុមអំពីរឿងប្រលោមលោកទំនើបៗ ការបោះពុម្ពផ្សាយអត្ថបទការសែត ការនិពន្ធកំណាព្យ ។ល។
- ***<u>ការវាយតម្លៃ៖</u>*** ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ។ សិស្សត្រូវបានអញ្ជើញឱ្យធ្វើសកម្មភាព ពីព្រោះពួកគេចង់ធ្វើ មិនមែនដោយសារតែគេបង្ខំឡើយ។
- ***<u>ការចូលរួម៖</u>*** សមាសភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- ***<u>ការប្រជុំ៖</u>*** ការប្រជុំគួរធ្វើទៀងទាត់ (ប្រហែល២ដង/សប្តាហ៍) ដើម្បីពិភាក្សាផែនការសកម្មភាពដែលបានគ្រោងទុក។ ការប្រជុំត្រូវធ្វើឡើងនៅក្រៅម៉ោងសិក្សា ឬពេលសាលាឈប់សម្រាក។

ផ្អែកតាមសេចក្តីណែនាំនេះ យើងត្រូវសួរសិស្សអំពីចំណាប់អារម្មណ៍របស់ពួកគេក្នុងការចូលរួមក្លឹបតាមរយៈការវាយតម្លៃកម្រិតចំណាប់អារម្មណ៍របស់ពួកគេ។ នៅពេលវាយតម្លៃចំណាប់អារម្មណ៍របស់សិស្ស យើងប្រើទម្រង់នៅក្នុង **ឧបសម្ព័ន្ធទី១**។ ទម្រង់នេះមានសារៈប្រយោជន៍ ពីព្រោះវានឹងទប់ស្កាត់មិនឱ្យសិស្សមានសម្ពាធចំពោះការនិយាយពាក្យព្រម ឬមិនព្រម ជាពិសេសនៅពេលគេមើលឃើញថា សិស្សបង្ហាញនូវភាពមិនចាប់អារម្មណ៍ អាចឆ្លុះបញ្ចាំងឃើញថាមិនគោរពគ្រូ។ ទុកពេលឱ្យសិស្ស ១០ ទៅ ១៥នាទី ដើម្បីពួកគេពិភាក្សា និងសម្រេចចិត្តមុនពេលបំពេញទម្រង់ចំណាប់អារម្មណ៍ និងជូនទម្រង់នោះមកឱ្យគ្រូវិញ។

### ៤.១.៥ ការបែងចែកភារកិច្ច

នៅក្នុងការប្រជុំក្លឹបលើកដំបូង គ្រូដែលមានភារកិច្ចទទួលខុសត្រូវក្លឹប ត្រូវរៀបចំជ្រើសរើសសមាជិកក្លឹបមួយចំនួនដើម្បីទទួលខុសត្រូវទៅតាមភារកិច្ច។ ការជ្រើសរើសនេះ អាចធ្វើឡើងដោយការបោះឆ្នោត ឬដោយការស្រែកលើកដៃ។ តួនាទីគឺមិនទៀងទាត់ទេ រួមមាន (១)ប្រធាន (២)អនុប្រធាន និង(៣)ហិរញ្ញិក។ ប្រសិនបើមានសិស្សច្រើននៅក្នុងក្លឹប (ឧ. ១៥នាក់ ឬច្រើនជាងនេះ) ចាំបាច់ត្រូវមានប្រធានក្រុមម្នាក់សម្រាប់សមាជិក ៣ ទៅ ៤នាក់។ ការទទួលខុសត្រូវសម្រាប់តួនាទីនីមួយៗ ត្រូវបានបង្ហាញនៅក្នុង**ឧបសម្ព័ន្ធទី២**។ ទំនួលខុសត្រូវទាំងនេះត្រូវបង្ហាញដល់សមាជិកក្លឹបទាំងអស់ ត្រូវពន្យល់ដោយគ្រូដឹកនាំក្លឹប។ ក្នុងជំហានដំបូងនៃសកម្មភាពក្លឹប គ្រូដែលមានភារកិច្ចទទួលខុសត្រូវលើការងារនេះ ត្រូវមានទំនាក់ទំនងល្អក្នុងការចូលរួមចំណែកជួយដល់សមាជិកក្លឹបដែលបានជ្រើសរើស និងជួយដល់ការបំពេញតាមតួនាទីរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ គ្រូដឹកនាំត្រូវបេះផ្ទេរការទទួលខុសត្រូវឱ្យបានច្រើនដល់សិស្ស ពេលពួកគេមានបទពិសោធន៍កាន់តែច្រើនក្នុងការបំពេញភារកិច្ចផ្សេងៗនៅអំឡុងឆ្នាំសិក្សានេះ។

### ៤.១.៦ ការកំណត់ផែនការ

កិច្ចការមួយក្នុងចំណោមការងារដំបូងគេដែលក្លឹបត្រូវធ្វើគឺ ការកំណត់ផែនការសកម្មភាពដែលបានស្នើសុំសម្រាប់អនុវត្តក្នុងរយៈពេល១ត្រីមាស។ ទម្រង់ផែនការដែលអាចជួយក្លឹបស្របតាមសកម្មភាពប្រចាំសប្តាហ៍នៃខែនីមួយៗ ត្រូវបានបង្ហាញក្នុង**ឧបសម្ព័ន្ធទី៣**។ មុនពេលបង្កើតផែនការ គ្រូដឹកនាំក្លឹបត្រូវព្យាយាមពិនិត្យឡើងវិញនូវសកម្មភាពមួយចំនួនដែលអាចធ្វើទៅបាន ហើយបង្កើតគម្រោង ១ ឬ ២ ដែលក្លឹបនឹងធ្វើនៅក្នុងពេល១ត្រីមាស។ ឧទាហរណ៍មួយចំនួនត្រូវបានផ្តល់ឱ្យជាគំរូនៅផ្នែកខាងក្រោម។ ឧទាហរណ៍. ក្លឹបប្រហែលជាចង់សរសេរអត្ថបទខ្លីបែបច្នៃប្រឌិតពីប្រាសាទមួយនៅក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយគ្រូជួយសម្របសម្រួលសកម្មភាពអំពីរបៀបសរសេរប្រភេទផ្សេងៗរបស់អត្ថបទ មុនពេលចាប់ផ្តើមទស្សនកិច្ចប្រាសាទ។ សកម្មភាពនេះ រួមមានទាំងកំណាព្យ ឬអត្ថបទរឿងនិទានខ្លីៗ។ គ្រូដឹកនាំក្លឹបត្រូវដើរតួនាទីជាអ្នកសម្របសម្រួលសកម្មភាពទាំងឡាយ រហូតទាល់តែសិស្សយល់ច្បាស់ពីរបៀបសរសេរ និងអាចអនុញ្ញាតឱ្យពួកគេសរសេរអត្ថបទដោយខ្លួនឯងបាន។ ប្រភេទនៃសកម្មភាពសំណេរត្រូវបានភ្ជាប់ជូននៅក្នុង **ឧបសម្ព័ន្ធទី៥** នៃឯកសារនេះ។ នៅពេលសំណេរអត្ថបទរបស់ពួកគេបានរួចរាល់ ក្លឹបត្រូវរៀបចំការតាំងពិព័រណ៍នៅក្នុងបណ្ណាល័យ ឬក្នុងថ្នាក់រៀន ព្រមទាំងធ្វើបទបង្ហាញដល់សិស្សផ្សេងទៀត ដែលមិនមែនជាសមាជិកក្លឹប។ សកម្មភាពទាំងអស់នេះត្រូវបានសរសេរឡើងក្នុងផែនការផងដែរ។ ឧទាហរណ៍មួយត្រូវបានផ្តល់ឱ្យនៅក្នុងតារាងខាងក្រោម៖

**តារាងទី១៖ ការកំណត់ផែនការ**

**ត្រីមាសទី១**

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| 1. <u>ការប្រជុំលើកទី ១៖</u> ការបោះឆ្នោត និងសកម្មភាពនិពន្ធ | x | | | | | | | | | | | |
| 2. <u>ការប្រជុំលើកទី ២៖</u> សកម្មភាពនិពន្ធ | | x | | | | | | | | | | |
| 3. <u>ការប្រជុំលើកទី ៣៖</u> សកម្មភាពនិពន្ធ | | | x | | | | | | | | | |
| 4. ការចុះតាមមូលដ្ឋាន | | | | x | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 5. សកម្មភាពនិពន្ធ | | | | | x | | | | | | | |
| 6. ផែនការតាំងពិព័រណ៍ | | | | | | x | | | | | | |
| 7. រៀបចំការតាំងពិព័រណ៍ | | | | | | | x | | | | | |
| 8. ការតាំងពិព័រណ៍បង្ហាញ | | | | | | | | x | | | | |

### ៤.១.៧ ការកំណត់ធនធាន

ដើម្បីឱ្យក្លឹបមានដំណើរការដោយប្រសិទ្ធភាព ក្លឹបត្រូវមានធនធានគាំទ្រ។ ធនធានទាំងនេះ រួមមានសម្ភារៈរូបវន្តដូចជា កន្លែងប្រជុំ (ឧ. បណ្ណាល័យ ថ្នាក់រៀនដែលទំនេរ ឬទីធ្លាណាមួយ) សៀវភៅរឿងប្រលោមលោក ឬទស្សនាវដ្ដី បន្ទប់កុំព្យូទ័រសម្រាប់វាយសំណេរបែបច្នៃប្រឌិត ឬធនធានថវិកា។ ធនធានថវិកាត្រូវប្រើសម្រាប់អនុវត្តសកម្មភាពជាក់លាក់ដូចខាងក្រោម៖

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ (គ្រប់ក្រុម)
- ក្រដាសផ្ទាំងធំសម្រាប់បង្កើតការតាំងពិព័រណ៍
- ហ្វឹតសម្រាប់រៀបចំការតាំងពិព័រណ៍
- ថវិកាសម្រាប់ការធ្វើដំណើរចុះមូលដ្ឋាន
- ម៉ាស៊ីនថតរូបសម្រាប់ថតរូប
- ថវិកាផ្សេងៗសម្រាប់គោលបំណងពិសេសផ្សេងៗទៀត
- ផ្សេងៗ

ការផ្ដល់ថវិកាគួរតែរៀបចំផែនការដោយគណៈកម្មការសាលា ដែលជាផ្នែកមួយនៃដំណើរការរៀបចំផែនការប្រចាំឆ្នាំ ដែលធ្វើឡើងនៅរៀងរាល់ដើមឆ្នាំ។ ការពន្យល់បកស្រាយអំពីថវិកាមាននៅក្នុង**ឧបសម្ព័ន្ធទី ៤**។

## ៤.២. សកម្មភាពស្នើឡើង

គេអាចរៀបចំសកម្មភាពច្រើនប្រភេទ ដើម្បីបង្កើនការរៀនសូត្ររបស់សិស្ស ដោយមិនចាំបាច់ទាមទារពេលវេលារបស់ពួកគេក្នុងការបំពេញកិច្ចការ ឬពេលវេលារបស់គ្រូដឹកនាំ ក្នុងការប្រជុំនិងការដាក់ពិន្ទុសិស្សឡើយ។ តាមការពិតអ្នកជំនាញផ្នែកនិពន្ធជាច្រើននាក់មិនយល់ស្របថា សិស្សចេះពីការសរសេរ អត្ថបទរឿងខ្លីៗជាងការសរសេរអត្ថបទវែង។ ចូរគិតថា ការសរសេរគឺជាវិធីមួយនៃការរៀនសូត្រ។ ការសរសេរ ធ្វើឱ្យសិស្សគិតដែលជាហេតុធ្វើឱ្យសិស្សរៀន។

មានសកម្មភាពសំណេរដែលគួរឱ្យចាប់អារម្មណ៍ជាច្រើន ដែលក្លឹបអាចរៀបចំហើយធានាថាវាជាសកម្មភាពដែលល្អ មានលក្ខណៈគិតវិភាគសម្រាប់សិស្សរៀន។ សកម្មភាពដែលត្រូវបានផ្ដល់ឱ្យនៅផ្នែកខាងក្រោម គឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ គ្រូដឹកនាំ និងសមាជិកក្លឹប អាចមានគំនិតផ្ទាល់ខ្លួនអំពីអ្វីដែល ពួកគេចង់ធ្វើប្រកបដោយលក្ខណៈច្នៃប្រឌិតតាមរយៈការនិពន្ធ។

### ៤.២.១. សំណេរច្នៃប្រឌិត (Creative Writing)

ការនិពន្ធច្នៃប្រឌិតគឺជាទម្រង់បញ្ចេញ21ចំណុចដែលត្រូវចាប់ផ្ដើមសរសេរ។ ដូច្នេះគ្រូដឹកនាំក្លឹបត្រូវយល់ដឹងពីបញ្ហានេះ ហើយចាប់ផ្ដើមការប្រជុំក្លឹបដោយធ្វើសកម្មភាពសំណេរបែបច្នៃប្រឌិត និងសប្បាយរីករាយ។ សិស្សនឹងមានអារម្មណ៍ល្អច្រើនដែលអាចបញ្ចេញនូវគំនិតបែបច្នៃប្រឌិតនៅក្នុងបរិយាកាសមួយដែលមានការគាំទ្រ ឧទាហរណ៍សំណេរបែបច្នៃប្រឌិត សូមមើលនៅ**ឧបសម្ព័ន្ធទី៥**។

### ៤.២.២. កំណាព្យ (Poetry)

កំណាព្យ គឺជាអត្ថបទនិពន្ធដែលបង្កើតអោយមានការយល់ដឹង បទពិសោធន៍បែបស្រមើស្រមៃតាមរយៈការប្រើប្រាស់ភាសា និងបញ្ចេញជាអារម្មណ៍ជាក់លាក់តាមរយៈអត្ថន័យ សំឡេង និងពាក្យចំណាប់ចុងជួន។ កំណាព្យមានលក្ខណៈខុសគ្នាពីភាសាដែលប្រើប្រាស់ប្រចាំថ្ងៃ តាមរយៈការបង្រួម ឬបង្គប់ន័យ បែបបទនៃការប្រើប្រាស់ព្យាង្គ និងចំណាប់ចុងជួន ការប្រើប្រាស់ឃ្លាបន្ទាត់ ការប្រើវាក្យសព្ទប្លែកៗ និងលំដាប់លំដោយពាក្យ (Syntax)។ ខ្លឹមសារកំណាព្យសម្តែងចេញតាមរយៈបច្ចេកទេសសម្បូរបែប ការបរិយាយដោយផ្ទាល់ទៅជានិមិត្តសញ្ញាតំណាង ដូចជាការប្រើប្រាស់ពាក្យប្រៀបធៀបដោយន័យត្រង់ (Metaphor) និងការប្រៀបធៀបដោយន័យធៀប (Simile)។

អត្ថប្រយោជន៍មួយទៀតនៃការនិពន្ធកំណាព្យ គឺសិស្សមានសេរីភាពបង្ហាញគំនិតផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រភេទកំណាព្យមានច្រើនសម្រាប់សិស្សជ្រើសរើស ហើយគ្រូគួរបង្ហាញនូវប្រភេទកំណាព្យទាំងអស់នោះ ដើម្បីឱ្យសិស្សបានជ្រើសរើសតាមតម្រូវការផ្ទាល់ខ្លួន។ ឧទាហរណ៍គំរូសម្រាប់សកម្មភាពនិពន្ធកំណាព្យសូមមើលនៅក្នុង**ឧបសម្ព័ន្ធទី ៦**។

### ៤.២.៣. ទិនានុប្បវត្តិ (Journals)

សិស្សភាគច្រើនចង់សរសេរសកម្មភាពប្រចាំថ្ងៃ ក្រោមបរិយាកាសគ្មានការគំរាមកំហែង។ សំណេរបែបទិនានុប្បវត្តិគេអាចធ្វើបានទាំងក្នុង និងក្រៅម៉ោងសិក្សា ហើយវាមិនចាំបាច់ត្រូវការរចនាសម្ព័ន្ធច្បាស់លាស់ឡើយ។ ជាការពិតណាស់សិស្សអាចជ្រើសរើសប្រធានបទសរសេរដោយសេរី ដែលគេអាចបកស្រាយ ឬឆ្លុះបញ្ចាំងផ្អែកលើបទពិសោធន៍ក្នុងជីវិត ដើម្បីពង្រីកបទពិសោធន៍យល់ដឹងរបស់ពួកគេ។ ប្រសិនបើអ្នកចង់មើលសំណេរបែបទិនានុប្បវត្តិដែលមានរចនាសម្ព័ន្ធ សូមមើលគំរូនៅក្នុង**ឧបសម្ព័ន្ធទី ៧** ។

### ៤.២.៤. សំបុត្រ (Letters)

សិស្សសរសេរសំបុត្រជាលក្ខណៈក្រៅផ្លូវការទៅកាន់មិត្តភក្តិរបស់ពួកគេ ហើយសំបុត្រទាំងនោះអាចសរសេរពីប្រធានបទណាក៏បាន។ អ្នកអាចបង្កើតជាសំណួរអំពីអំណាន ឬអំពីការនិពន្ធរបស់សិស្ស (ឧ. ប្រសិនបើពួកគេកំពុងសរសេររឿងខ្លីណាមួយ) ដើម្បីឱ្យយល់អំពីគំនិតរបស់សិស្សក្នុងការសរសេរ។ សិស្សអាចផ្លាស់ប្តូរសំបុត្រគ្នាទៅវិញទៅមក (អាចប្តូរជាមួយសិស្សនៅក្នុងថ្នាក់ ឬ សិស្សដទៃទៀត) អំពីប្រធានបទពាក់ព័ន្ធនឹងការរៀនក្នុងថ្នាក់ ឬពាក់ព័ន្ធជីវិតរស់នៅជាក់ស្តែងរបស់ពួកគេ ឬពាក់ព័ន្ធនឹងសាលារៀន។

### ៤.២.៥. ការបោះពុម្ព (Publications)

សិស្សអាចចូលរួមជាមួយមិត្តភក្តិធ្វើកិច្ចការបោះពុម្ពស្នាដៃនិពន្ធរបស់ពួកគេ ជាមួយក្លឹបព្រឹត្តិបត្រសាលារៀន។ ព្រឹត្តិបត្រគួរបញ្ចូលស្នាដៃនិពន្ធបែបច្នៃប្រឌិត បំណកស្រាយបែបរូបភាព ឬសេចក្តីជូនដំណឹងពីព្រឹត្តិការណ៍សហគមន៍ដែលនឹងគ្រោងធ្វើនាពេលខាងមុខ។ នៅពេលបង្កើតព្រឹត្តិបត្រ ការផ្តល់បរិយាកាសឱ្យសិស្សធ្វើការច្នៃប្រឌិតគឺមានសារៈសំខាន់ណាស់។ ការបង្កើតចំណងជើង និងប្លង់ព្រឹត្តិបត្រដោយខ្លួនឯងជំរុញឱ្យពួកគេមានភាពម្ចាស់ការ។ ព្រឹត្តិបត្រសាលារៀនផ្តល់ជាវេទិកាសម្រាប់សិស្សផ្សព្វផ្សាយការងាររបស់ពួកគេយ៉ាងទៀងទាត់ពេញមួយឆ្នាំសិក្សា។

ជម្រើសមួយទៀតក្នុងការបោះពុម្ពព្រឹត្តិបត្រ គឺការបោះពុម្ពសំណៅច្នៃប្រឌិតរបស់សមាជិកក្លឹបនៅចុងបញ្ចប់ត្រីមាស។ សិស្សអាចជ្រើសរើសលទ្ធផលកិច្ចការដែលពួកគេមានមោទនភាពបំផុត ដែលចង់ចែករំលែក

ទៅឱ្យមិត្តភក្តិរបស់ពួកគេ។ លទ្ធផលចុងក្រោយអាចរក្សាទុកនៅក្នុងបណ្ណាល័យ ឬបន្ទប់ក្លឹបមុខវិជ្ជាដើម្បីឱ្យសិស្សផ្សេងទៀតបានយល់ពីតម្លៃស្នាដៃ។

### ៤.២.៦. ការប្រជុំឱ្យតម្លៃស្នាដៃនិពន្ធ

កិច្ចប្រជុំនេះមានសារៈសំខាន់ដើម្បីលើកទឹកចិត្តសិស្សឱ្យចូលចិត្តអាន ការឱ្យតម្លៃស្នាដៃរបស់អ្នកដទៃ និងការបណ្តុះទឹកចិត្តផងដែរ។ គ្រូអាចជ្រើសរើសអត្ថបទរឿងខ្លីៗអោយសិស្សអានដោយខ្លួនឯងនៅពេលណាមួយ ហើយបន្ទាប់មកទៀតពិភាក្សាគ្នានៅពេលជួបគ្នាក្នុងការប្រជុំក្លឹប។ ឬមួយក៏គ្រូអាចជ្រើសរើសរឿងខ្លីមួយ ឬកម្រងកំណាព្យមួយ ហើយសិស្សអាចផ្លាស់វេនគ្នាអានអត្ថបទនោះឱ្យលឺៗ ហើយពិភាក្សារួមគ្នា។ គំនិតសម្រាប់សំណួរពិភាក្សាមាននៅក្នុង**ឧបសម្ព័ន្ធទី ៨**។ ម៉្យាងវិញទៀត គ្រូអាចជ្រើសរើសរឿងប្រលោមលោកមួយសម្រាប់សិស្សអាននៅជំពូកណាមួយ ហើយពិភាក្សានៅពេលជួបគ្នានៅក្នុងការរៀនក្លឹប។ វាក៏ជាគំនិតល្អផងដែរ ក្នុងការឱ្យសិស្សអានកិច្ចការរបស់សមាជិកក្លឹប បន្ទាប់មកផ្តល់ឱកាសឱ្យពួកគេផ្តល់ព័ត៌មានត្រឡប់។

### ៤.២.៧ ការឆ្លុះបញ្ចាំងពីដំណើរទស្សនកិច្ច

ក្លឹបនិពន្ធអាចធ្វើដំណើរទៅកាន់ទីកន្លែង ដែលគួរឱ្យចាប់អារម្មណ៍ណាមួយនៅក្នុងមូលដ្ឋាន ដើម្បីជាសកម្មភាពមួយបណ្តុះគំនិតសំណេរបែបច្នៃប្រឌិត (ឧ. ប្រាសាទបុរាណ ទឹកជ្រោះ ឆ្នេរសមុទ្រ វាលខ្សាច់ ភ្នំ និងព្រៃ។ល។) សិស្សអាចសរសេរអំពីបទពិសោធន៍ ដែលពួកគេជួបប្រទះជាទម្រង់បែបទិនានុប្បវត្តិ កំណាព្យ ប្រវត្តផ្ទាល់ខ្លួន។ល។

### ៤.២.៨. ការទំនាក់ទំនងរោងពុម្ពក្នុងមូលដ្ឋានសម្រាប់បោះពុម្ពអត្ថបទរឿងរបស់សិស្ស

គ្រូដឹកនាំក្លឹបអាចទំនាក់ទំនងជាមួយរោងពុម្ពក្នុងមូលដ្ឋាន (ឧ. ខេត្តកំពង់ចាម) និងទស្សនាវដ្តី (ឧ. ទស្សនាវដ្តី មុំ និងម៉ាប់) ដើម្បីបោះពុម្ពសំណេរច្នៃប្រឌិតរបស់សិស្ស។

## ៤.៣. ការប្រជុំឆ្លុះបញ្ចាំងដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំ

ការប្រជុំនេះអាចធ្វើឡើងបែបជាការធ្វើទស្សនកិច្ចទៅកាន់មូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងនូវបរិយាកាសល្អពីអ្វីដែលបាន កើតឡើងនៅក្នុងក្លឹបរយៈពេលមួយឆ្នាំ។ សិស្សអាចចំណាយពេលដើម្បីអាននូវអ្វីដែលពួកគេពេញចិត្តពីម្នាក់ទៅម្នាក់ក្នុងរយៈពេលមួយឆ្នាំ។ គ្រូដឹកនាំក្លឹបអាចចំណាយពេលដើម្បីរៀបចំការវាយតម្លៃខ្លីៗទៅលើក្លឹប ដើម្បីកែលម្អសម្រាប់ឆ្នាំក្រោយ។

## ឧបសម្ព័ន្ធទី ១ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស

### សេចក្តីផ្តើម

ការចូលរួមក្លឹបនិពន្ធគឺជាឱកាសមួយក្នុងការគិតតាមរយៈសកម្មភាពសំណេរច្នៃប្រឌិត។ នេះគឺជាចំនុចមួយចំនួនដែលអ្នកគួរតែដឹង នៅមុនពេលអ្នកសម្រេចចិត្តថាតើត្រូវចូលរួមក្លឹប ឬមិនចូលរួម៖

- ***វត្ថុបំណង៖*** ផ្តល់បរិយាកាសជាវិជ្ជមាន និងគ្មានការគំរាមកំហែងចំពោះការអភិវឌ្ឍបំណិនសរសេរ។
- ***សកម្មភាព៖*** ការចុះតាមមូលដ្ឋាន ការសរសេរកំណត់ត្រាប្រចាំថ្ងៃ ការពិភាក្សាក្រុមអំពីរឿងប្រលោមលោកទំនើបៗ ការបោះពុម្ពផ្សាយអត្ថបទការសែត ការនិពន្ធកំណាព្យ ។ល។
- ***ការវាយតម្លៃ៖*** ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ។ សិស្សអនុញ្ញាតឱ្យធ្វើសកម្មភាពពីព្រោះពួកគេចង់ធ្វើ មិនមែនដោយសារតែគេបង្ខំឡើយ។
- ***ការចូលរួម៖*** សមាសភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- ***ការប្រជុំ៖*** ការប្រជុំគួរធ្វើទៀងទាត់ (ប្រហែល២សប្តាហ៍ម្តង) ដើម្បីពិភាក្សាផែនការសកម្មភាពបានគ្រោងទុក។ ការប្រជុំត្រូវធ្វើឡើងនៅក្រៅម៉ោងសិក្សា ឬពេលសាលាឈប់សម្រាក។

### សំណួរ

សូមបញ្ជាក់ពីកម្រិតចំណាប់អារម្មណ៍របស់អ្នកក្នុងការចូលរួមក្លឹបនិពន្ធ ដោយគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងក្រោមនេះ៖

☐ ខ្ញុំមិនចាប់អារម្មណ៍នឹងការចូលរួមក្លឹបនិពន្ធនេះទេ។

☐ ខ្ញុំចាប់អារម្មណ៍នឹងការចូលរួមក្លឹបនិពន្ធ ប៉ុន្តែខ្ញុំមិនប្រាកដថាមានពេលចូលរួមនោះទេ។

☐ ខ្ញុំចាប់អារម្មណ៍ចូលរួមក្លឹបនិពន្ធខ្លាំងណាស់ ហើយខ្ញុំប្រាកដថាមានពេលវេលាគ្រប់គ្រាន់ចូលរួម។

## ឧបសម្ព័ន្ធទី ២. ការបែងចែកភារកិច្ច

### ១. ប្រធាន

- រៀបចំការប្រជុំក្លឹប
- សម្របសម្រួលរៀបចំរបៀបវារៈសម្រាប់ការប្រជុំនីមួយៗ
- សម្របសម្រួលការប្រជុំ
- ធានាថាកន្លែងប្រជុំអាចប្រើប្រាស់បាន ដោយធ្វើការសម្របសម្រួលជាមួយនឹងនាយកសាលា
- ទំនាក់ទំនងជាមួយនឹងសមាជិកក្លឹប និងគណកម្មការសាលាធនធាន
- តាមដានការអនុវត្តផែនការសកម្មភាពក្រុម
- រាយការណ៍ពីបញ្ហានានាដល់គ្រូដឹកនាំក្លឹប ប្រសិនបើមាន

### ២. អនុប្រធាន

- បំពេញតួនាទីជាប្រធាន នៅពេលប្រធានអវត្តមាន
- ជួយសម្របសម្រួលការប្រជុំ
- សរសេរកំណត់ហេតុប្រជុំ

### ៣. ហិរញ្ញិក

- ទទួលខុសត្រូវចំពោះថវិកា ដែលបានផ្តល់ឱ្យដោយគ្រូដឹកនាំក្លឹបសម្រាប់សកម្មភាពផ្សេងៗ រួមមានការស្នើរទិញសម្ភារៈសម្រាប់តាំងពិព័រណ៍ ការចុះតាមមូលដ្ឋាន។ល។
- ថែរក្សាទុកកំណត់ត្រាថវិកាទាំងអស់ពេលដែលទទួលបានពីគ្រូដឹកនាំក្លឹប។
- រៀបចំសំណើ ឬ ចំណាយតាមការណែនាំរបស់គ្រូដឹកនាំក្លឹប។

### ៤. ប្រធានក្រុម

- ផ្តល់ភាពជាអ្នកដឹកនាំដល់ក្រុម
- ធ្វើរបាយការណ៍ក្នុងនាមតំណាងក្រុមជូនដល់ប្រធានក្លឹប ឬគ្រូដឹកនាំក្លឹប
- ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធានក្លឹប ឬគ្រូដឹកនាំក្លឹបដល់សមាជិកក្រុម

### ៥. គ្រូដឹកនាំក្លឹប

- ផ្តល់ការណែនាំទូទៅពីគោលការណ៍ក្លឹបក្នុងការរៀបចំផែនការប្រជុំ ដឹកនាំការប្រជុំ ជ្រើសរើសប្រធានផ្នែកក្លឹប ធានាថាប្រធានផ្នែកក្លឹបអាចធ្វើការងារជាច្រើនបានដោយខ្លួនរបស់ពួកគេ។
- ផ្តល់ការគាំទ្របច្ចេកទេសពីបញ្ហាទាក់ទងនឹងក្លឹបនិពន្ធ (សម្របសម្រួលសម្ភារៈរូបវន្ត តាមដានការប្រើប្រាស់ដំណើរការសម្ភារៈ។ល។)
- តំណាងឱ្យក្លឹបប្រចាំគណៈកម្មការទ្រទ្រង់សាលាក្នុងពេលដំណើរការរៀបចំថវិកា។
- សម្របសម្រួលសកម្មភាពផ្សេងៗដូចជា ការរៀបចំផែនការ និងការធ្វើដំណើរចុះមូលដ្ឋាន។
- សម្របសម្រួលការទំនាក់ទំនងរវាងក្លឹប និងរដ្ឋបាលសាលាសម្រាប់គោលបំណងផ្សេងៗ ដូចជាការប្រើប្រាស់បណ្ណាល័យសម្រាប់ការប្រជុំជាដើម។
- ត្រួតពិនិត្យការប្រើប្រាស់ធនធានថវិការបស់ក្លឹប។

# ឧបសម្ព័ន្ធទី ៣ ការកំណត់ផែនការ

ត្រីមាសទី ១៖

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| 1. | | | | | | | | | | | | |
| 2. | | | | | | | | | | | | |
| 3. | | | | | | | | | | | | |
| 4. | | | | | | | | | | | | |
| 5. | | | | | | | | | | | | |
| 6. | | | | | | | | | | | | |
| 7. | | | | | | | | | | | | |
| 8. | | | | | | | | | | | | |
| 9. | | | | | | | | | | | | |
| 10. | | | | | | | | | | | | |
| 11. | | | | | | | | | | | | |
| 12. | | | | | | | | | | | | |
| 13. | | | | | | | | | | | | |
| 14. | | | | | | | | | | | | |
| 15. | | | | | | | | | | | | |

ត្រីមាសទី ២៖

| សកម្មភាព | កុម្ភៈ | | | | មិនា | | | | មេសា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| 1. | | | | | | | | | | | | |
| 2. | | | | | | | | | | | | |
| 3. | | | | | | | | | | | | |
| 4. | | | | | | | | | | | | |
| 5. | | | | | | | | | | | | |
| 6. | | | | | | | | | | | | |
| 7. | | | | | | | | | | | | |
| 8. | | | | | | | | | | | | |
| 9. | | | | | | | | | | | | |
| 10. | | | | | | | | | | | | |
| 11. | | | | | | | | | | | | |
| 12. | | | | | | | | | | | | |
| 13. | | | | | | | | | | | | |
| 14. | | | | | | | | | | | | |
| 15. | | | | | | | | | | | | |

## ឧបសម្ព័ន្ធទី ៤៖ ការកំណត់ធនធាន

| ការចំណាយ | ឯកត្តា | ចំនួន |
|---|---|---|
| 1. ក្រដាសផ្ទាំងធំ | ១ kg x ៨,០០០៛/kg | ៨,០០០៛ |
| 2. ហ្វឺតសរសេរក្តារខៀន | ១ ប្រអប់ x ១០,០០០៛/ប្រអប់ | ២០,០០០៛ |
| 3. ក្រដាសពណ៌ | ២ រ៉ាម x ១៦,០០០៛/រ៉ាម | ៣២,០០០៛ |
| 4. ការបោះពុម្ពសំណេរ | -- | ៤០,០០០៛ |
| 5. ការចុះមូលដ្ឋាន #1៖<br>អាហារថ្ងៃត្រង់៖<br>រថយន្តឈ្នួល៖<br>ម៉ាស៊ីនថតរូប៖ | <br>១៥ នាក់ x ៤,០០០៛/ នាក់<br>១០០,០០០៛/ថ្ងៃ x ១ ថ្ងៃ<br>ម៉ាស៊ីនថតផ្ទាល់ខ្លួន ឬទូរស័ព្ទដៃ | <br>៦០,០០០៛<br>១០០,០០០៛<br>--------------<br>១៦០,០០០៛ |
| 6. ការចុះមូលដ្ឋាន #2៖<br>អាហារថ្ងៃត្រង់៖<br>រថយន្តឈ្នួល៖<br>ម៉ាស៊ីនថតរូប៖ | <br>15 នាក់ x $1/នាក់<br>$25/ ថ្ងៃ x 1 ថ្ងៃ<br>ម៉ាស៊ីនថតផ្ទាល់ខ្លួន ឬទូរស័ព្ទដៃ | <br>៦០,០០០៛<br>១០០,០០០៛<br>--------------<br>១៦០,០០០៛ |
| សរុប | | ៤២០,០០០ រៀល |

## ឧបសម្ព័ន្ធទី ៥៖ សកម្មភាពសំណេរបែបច្នៃប្រឌិត

<u>សម្គាល់៖</u> ផែនការសកម្មភាពនីមួយៗមានកំណត់ពេលរួចជាស្រេច ប៉ុន្តែត្រូវធានាថាផ្តល់ពេលវេលាឱ្យសិស្សតាមតម្រូវការ។ សិស្សមួយចំនួនអាចត្រូវការពេលវេលាយូរក្នុងការគិត និងបង្ហាញគំនិតរបស់ពួកគេ។ សកម្មភាពទាំងនេះគឺជាមធ្យោបាយរីករាយមួយសម្រាប់បង្កឱ្យសិស្សបញ្ចេញនូវភាពច្នៃប្រឌិត ហើយបន្តសកម្មភាពនិពន្ធដោយខ្លួនឯងក្នុងពេលទំនេររបស់ពួកគេ។

### <u>1. ការនិពន្ធពីកំណប់ដែលបានរកឃើញ</u>




**វត្ថុបំណង** ៖ សកម្មភាពនេះគឺជាវិធីដ៏ល្អមួយឱ្យសិស្សយល់កាន់តែច្បាស់អំពីដំណើរការសំណេរបែបច្នៃប្រឌិត។

**សម្ភារៈ** ៖ ហិបដាក់វត្ថុផ្សេងៗ

**ពេលវេលា** ៖ ១ – ២ម៉ោង

**ដំណើរការ** ៖ ប្រមូលរបស់កំប៉ិចកំប៉ុក ហើយរៀបដាក់ក្នុងថង់ក្រដាសតូចៗ។ អ្នកអាចដាក់អ្វីៗផ្សេងទៀត ដូចជាដុំថ្ម ក្រដាសចោលមួយសន្លឹក រោមសត្វមួយ រូបថតរបស់ក្មេងស្រីណាមួយ និងរូបផ្កែរបស់នាង ឡេវអាវ និងអ្វីៗផ្សេងៗទៀត។ អ្នកត្រូវមានថង់សម្រាប់សិស្សគ្រប់គ្នា ហើយថង់មួយសម្រាប់សិស្សមួយក្រុម ឬថង់មួយសម្រាប់សិស្សមួយថ្នាក់។

**កិច្ចការ៖** ហិបមួយដែលអ្នកបានទទួល មានផ្ទុកគ្រឿងរតនសម្បត្តិជាច្រើនដែលត្រូវបានគេទុកឱ្យ។ កិច្ចការរបស់អ្នក គឺត្រូវសរសេររឿងខ្លីមួយដែលពណ៌នាអំពីតួអង្គដែលបានប្រមូលវត្ថុទាំងនោះ ហើយបង្ហាញថាតើហេតុអ្វីបានជាវត្ថុទាំងនោះសំខាន់សម្រាប់តួអង្គនោះ។ តើវត្ថុទាំងនោះមានដំណើររឿងដូចម្តេច? ហេតុអ្វីបានជាតួអង្គនោះថែរក្សាទុកនូវវត្ថុទាំងនោះ? តើវត្ថុនោះអាច ប្រាប់អ្នកអំពីអ្វីខ្លះពីតួអង្គនោះ? តើតួអង្គនោះមានអាយុប៉ុន្មានឥឡូវនេះ ហើយតើគាត់មានអាយុប៉ុន្មានកាលពេលគាត់រើសបានវត្ថុទាំងនោះ? តើអ្នកគិតថាវត្ថុទាំងនោះគឺជារបស់ដែលតួអង្គបានទុកចោលនៅក្នុងជំនាន់របស់គាត់ដែរឬទេ? ចូរសរសេររឿងមួយអំពីវត្ថុទាំងនេះ?

### <u>២. ដំណើររឿងមិនតាមលំដាប់លំដោយ</u>

វត្ថុបំណង ៖ សកម្មភាពនេះគឺជាវិធីដ៏ល្អមួយឱ្យសិស្សយល់កាន់តែច្បាស់អំពីដំណើរការសំណេរបែបច្នៃប្រឌិត។

សម្ភារៈ ៖ បញ្ជីតួអង្គ/ទីកន្លែង/ពេលវេលា/ស្ថានភាព និងបញ្ហាប្រឈម សម្រាប់ជាឯកសារយោងរបស់គ្រូ

ពេលវេលា ៖ ១ - ២ ម៉ោង

ដំណើរការ ៖ ឱ្យសិស្សជ្រើសរើស៣លេខ (ពីលេខ ១ ដល់លេខ ១០)។ លេខនីមួយៗត្រូវគ្នានឹងវត្ថុមួយនៅក្នុងបញ្ជីខាងក្រោម។ លេខទី១គឺជាតួអង្គសំខាន់នៅក្នុងរឿង លេខទី២គឺជាទីកន្លែង ។ល។

**កិច្ចការ៖** ចូរសរសេររឿងមួយដោយប្រើតួអង្គ ទីកន្លែង ពេលវេលា និងស្ថានភាពដែលអ្នកបានជ្រើសរើស។ តួដែលអ្នកបានជ្រើសរើសគួរតែជាតួអង្គឯកនៅក្នុងរឿង ប៉ុន្តែមិនមែនចាំបាច់តែតួអង្គនៅក្នុងរឿងនោះទេ។ ដូចគ្នានេះដែរ ទិដ្ឋិភាពភាគច្រើននៃសាច់រឿងកើតនៅកន្លែងដែលអ្នកបានជ្រើសរើស ប៉ុន្តែអ្នកអាចរាប់បញ្ចូលទីកន្លែងផ្សេងៗ ឬបកស្រាយរៀបរាប់ពីទីកន្លែងដែលបានជ្រើសរើសនោះ (ឧ. បំបែកសាច់រឿងទៅជាផ្នែកតូចៗ)។ ស្ថានភាព ឬបញ្ហាប្រឈមដែលអ្នកបានជ្រើសរើសអាចទាក់ទងនឹងតួអង្គឯក ឬតួអង្គឯកអាចសង្កេតនរណាម្នាក់ផ្សេងទៀតដែលមានទំនាក់ទំនងជាមួយនឹងស្ថានភាព ឬបញ្ហាប្រឈមនោះ។ មួយវិញទៀត អ្នកអាចបញ្ចូលធាតុទាំងនេះតាមវិធីណាក៏បាន ដែលអ្នកចង់បាន ឱ្យតែបញ្ចូលចំណុចទាំង៤ខាងលើ។

| |
|---|
| **ឧទាហរណ៍នៃបញ្ជីលេខ សម្រាប់ជាឯកសារគ្រូ**<br>**តួអង្គ**<br>1. ម្តាយម្នាក់<br>2. អ្នកថតរូបម្នាក់<br>3. សិស្សដែលទើបបញ្ចប់ថ្នាក់វិទ្យាល័យម្នាក់<br>4. ម្ចាស់ភោជនីដ្ឋាន ឬអ្នកគ្រប់គ្រងម្នាក់<br>5. មនុស្សចម្លែកមកពីអវកាស<br>6. ក្មេងអនាថាម្នាក់<br>7. ស្ត្រីអាយុ៩៣ឆ្នាំម្នាក់<br>8. អ្នកបរិស្ថាននិយមម្នាក់<br>9. សិស្សមហាវិទ្យាល័យម្នាក់<br>10. តន្ត្រីករ Jazz ម្នាក់ |
| **ទីកន្លែង**<br>1. នៅជិតព្រៃ<br>2. កន្លែងទទួលភ្ញៀវនៅពិធីមង្គលការ<br>3. ពិធីជប់លៀងមួយកន្លែង<br>4. ភោជនីយដ្ឋានមួយកន្លែង<br>5. ហាងលក់ឥវ៉ាន់<br>6. ឧទ្យានទីក្រុង<br>7. យ៉ាផ្ទះកសិដ្ឋានចាស់មួយ<br>8. ប្រឡាយបង្ហូរជាតិពុល<br>9. បណ្ណាល័យរបស់មហាវិទ្យាល័យ<br>10. សាលមហោស្រពតន្ត្រី |

| |
|---|
| **ពេលវេលា**<br>1. ពេលភ្លើងឆេះព្រៃ<br>2. បន្ទាប់ពីវាយគ្នា<br>3. នៅយប់ថ្ងៃប្រលងបញ្ចប់ថ្នាក់វិទ្យាល័យ<br>4. បន្ទាប់ពីហូបអាហាររួច<br>5. ពេលណាមួយក្នុងខែធ្នូ<br>6. យប់ជ្រៅ<br>7. បន្ទាប់ពីមានព្យុះផ្គររន្ទះកើតឡើង<br>8. នៅដើមរដូវរំហើយ<br>9. សប្តាហ៍ទីមួយនៃឆ្នាំសិក្សា<br>10. នៅពេលប្រគុំតន្ត្រី |
| **ស្ថានភាព/បញ្ហាប្រឈម**<br>1. ត្រូវការធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ<br>2. សារភាពអាថ៌កំបាំងដល់នរណាម្នាក់<br>3. មោទនភាពរបស់នរណាម្នាក់បានបង្កឱ្យមានគ្រោះថ្នាក់<br>4. ការស្លាប់បានកើតឡើង<br>5. មាននរណាម្នាក់បានរកឃើញ ឬបាត់អ្វីមួយ<br>6. មនុស្សម្នាក់ជំរុញឱ្យមនុស្សម្នាក់ទៀតធ្វើខុស<br>7. រំលឹកឡើងនូវមធ្យោបាយដែលធ្វើឱ្យអ្វីៗបានផ្លាស់ប្តូរ<br>8. មនុស្សម្នាក់មានអារម្មណ៍ថាចង់លះបង់<br>9. រឿងគួរឱ្យអាម៉ាស់បានកើតឡើង<br>10. មាននរណាម្នាក់បានឈានដល់គោលដៅដ៏សំខាន់មួយ |

៣. សំបុត្រនៅក្នុងដប (A Message in a Bottle)



**វត្ថុបំណង** ៖ សិស្សម្នាក់ៗនឹងបង្កើតសំណេរច្នៃប្រឌិតពីការធ្វើដំណើរផ្សងព្រេង។

**សម្ភារៈ** ៖ ផែនទីពិភពលោក សៀវភៅផែនទី ដបជ័រមានគម្រប (មួយសម្រាប់សិស្សម្នាក់ ឬមួយក្រុម សម្រាប់សរសេររឿង ធុងចិញ្ចឹមត្រី ឬអាងទឹក (ប្រសិនបើមាន)

**ដំណើរការ** ៖

1. ប្រាប់សិស្សថា ពួកគេម្នាក់ៗនឹងសរសេររឿងពីការធ្វើដំណើរផ្សងព្រេងបែបស្រមើស្រម៉ៃមួយ ឬការធ្វើដំណើរមួយដែលបានធ្វើឱ្យគេជាប់នៅលើកោះ។ ចូរពន្យល់ថា ឱកាសតែមួយគត់សម្រាប់ការជួយសង្គ្រោះគឺ សរសេរសារមួយដាក់ចូលក្នុងដប ហើយដាក់ដបបណ្តែតទឹកដោយសង្ឃឹមថានឹងមាននរណាម្នាក់ឃើញវា។

2. គិតជាមួយសិស្សអំពីប្រភេទនៃព័ត៌មាន ដែលពួកគេគួរតែសរសេរបញ្ចូលនៅក្នុងរឿងរបស់ពួកគេ។ ឧទាហរណ៍ ពួកគេអាចចង់ពន្យល់ថាតើពួកគេនៅកន្លែងណា ពួកគេនឹងទៅកន្លែងណា ពួកគេជាប់គាំងនៅពេលណា ពួកគេមកពីណា ហើយតើពួកគេធ្វើដំណើរយ៉ាងដូចម្តេច។ សិស្សគួរតែសរសេរផងដែរនូវព័ត៌មានអំពីថា តើពួកគេនៅឯណា តើកោះនោះយ៉ាងដូម្តេចដែរ អាកាសធាតុយ៉ាងណា តើសត្វ និងរុក្ខជាតិអ្វីដែលពួកគេបានឃើញ ហើយតើពួកគេរួចផុតជីវិតដោយរបៀបណា។ ចូរកត់ត្រានូវសំណូមពររបស់ពួកគេនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
3. នៅពេលសិស្សរៀបចំខ្លួនក្នុងការសរសេររួចរាល់ហើយ បង្កើតជាផែនទី ឬសៀវភៅផែនទី ដែលឱ្យពួកគេអាចប្រើប្រាស់បាន។ សិស្សអាចមើលផែនទី ប្រសិនបើពួកគេត្រូវប្រើជាជំនួយក្នុងការធ្វើផែនការពីការធ្វើដំណើររបស់ពួកគេ ឬប្រកបឈ្មោះទីកន្លែងដែលពួកគេចង់សរសេរនៅក្នុងរឿងនោះ។
4. នៅពេលសិស្សសរសេររួច ឱ្យពួកគេដាក់រឿងចូលទៅក្នុងដប ហើយប្រមៀលដបលើគុប្រៀបបីដូចជាទឹកហូរ (ឬធុងអ្វីផ្សេងទៀតដែលអាចប្រើប្រាស់បាន)។
5. បន្ទាប់មកទៀត ឱ្យសិស្សម្នាក់ៗស្ទូចដប (មិនមែនជាកម្មសិទ្ធិរបស់ពួកគេ)ពីក្នុងទឹកហើយអានវាឱ្យលឺៗ។ បន្ទាប់ពីអានចប់រឿងនីមួយៗ សិស្សអាចសង្គ្រោះអ្នកសរសេរសំបុត្របាន ដោយប្រើផែនទី និងព័ត៌មានលម្អិតនៃសាច់រឿងដើម្បីស្វែងរកឱ្យឃើញថា តើមនុស្សនោះបានជាប់គាំងនៅឯណា។

## <u>៤. ទស្សនាវដ្តីអស្ចារ្យ</u>

**វត្ថុបំណង** ៖ ឱ្យសិស្សចេះបង្កើតរឿងដោយប្រើប្រាស់បំណែកអត្ថបទរឿងប្រើទស្សនាវដ្តីជាជំនួយ

**សម្ភារៈ** ៖

- ទស្សនាវដ្តីចាស់ៗដែលមានរូបភាព/ប្រធានបទផ្សេងៗ
- កាវ ឬស្កុត
- ក្រដាសផ្ទាំងធំ ឬតូចទំហំប៉ុនខិតប័ណ្ណផ្សព្វផ្សាយ
- កន្រ្តៃ

**ពេលវេលា** ៖ ១ - ២ម៉ោង

**ដំណើរការ** ៖

1. សិស្សអាចធ្វើការម្នាក់ឯង ជាដៃគូ ឬជាក្រុមតូចៗ
2. អ្នកនិពន្ធ/ក្រុមអ្នកនិពន្ធទទួលសឺមីមួយដែលមានរូបភាពទស្សនាវដ្តីមួយឈុត។ សាច់រឿងមួយត្រូវបង្កើតឡើងដោយប្រើរូបភាពយ៉ាងហោច ៥ (តួអង្គលាយបញ្ចូលគ្នា) ឧ. បុរសវ័យក្មេងទាំងអស់នៅក្នុងរឿង គឺឈ្មោះJohn ទោះបីជាពួកគេមានមុខមាត់ខុសគ្នាក៏ដោយ)។
3. ប្រសិនបើមានអ្នកនិពន្ធច្រើន ត្រូវតែចែករំលែកការនិទានរឿងឱ្យបានស្មើៗគ្នា។

**ជម្រើសមួយផ្សេងទៀត**

1. សិស្សអាចធ្វើការម្នាក់ឯង ជាដៃគូ ឬជាក្រុមតូចៗ
2. អ្នកនិពន្ធ/ក្រុមអ្នកនិពន្ធទទួលសឺមីមួយដែលមានរូបភាពទស្សនាវដ្តីមួយឈុត ហើយជ្រើសរើសយករូបភាពគួរឱ្យចាប់អារម្មណ៍ចំនួន ៤-៥ សម្រាប់ប្រើជាការនិទានរឿង។

**៥. ការនិទានពីទីកន្លែងកាលពីនៅកុមារភាព**

**វត្ថុបំណង** ៖ ឱ្យសិស្សចេះបញ្ចូលសំណេរច្នៃប្រឌិត

**សម្ភារៈ** ៖ ខ្មៅដៃ និងក្រដាស

**ពេលវេលា** ៖ តាមតម្រូវការ

**ដំណើរការ** ៖ ណែនាំឱ្យសិស្សគិតអំពីទីកន្លែងសំខាន់មួយ ឬព្រឹត្តការណ៍មួយកាលនៅកុមារភាព។ សរសេររឿងប្រឌិតមួយស្ដីពីកុមារម្នាក់ដែលតែងទៅកន្លែងនោះ ឬចូលរួមក្នុងព្រឹត្តការណ៍នេះ ដោយយកគំរូតាម**សៀវភៅកុមារ** ដែលនិយាយពីមនុស្សម្នាក់មានអាយុប្រហាក់ប្រហែលគ្នា។ ដោយសារពួកគេកំពុងសរសេរកំណត់ត្រាពីទីកន្លែង ឬព្រឹត្តការណ៍ណាមួយនោះ រាល់ព័ត៌មានលម្អិតរបស់គេមិនចាំបាច់ឱ្យដូចគ្នាទៅនឹងការពិតជាក់ស្ដែងទេ។ ពួកគេអាចបញ្ចូលព័ត៌មានដែលគេចងចាំ ២ ឬ ៣ (ឬច្រើន) ដាក់បញ្ចូលនៅក្នុងរឿងបាន។ ពួកគេអាចច្នៃប្រឌិតឡើងពីទីកន្លែងដែលពួកគេមិនបានចាំច្បាស់ ឬអ្វីដែលគេសង្ឃឹមថាអាចកើតឡើង។ រឿងរបស់ពួកគេគួរបង្ហាញអំពីការគិត និងអារម្មណ៍ចំពោះទីកន្លែង ឬព្រឹត្តការណ៍នោះកាលពីនៅវ័យកុមារ។ អ្នកអានមិនដែលធ្លាប់បានទៅកន្លែងនោះទេកាលពីមុនមក ដូច្នេះពួកគេនឹងត្រូវប្រើព័ត៌មានលម្អិត ហើយច្បាស់លាស់ ដែលធ្វើឱ្យគេស្គាល់កន្លែងនោះកាន់តែច្បាស់លាស់។

គ្រូបញ្ជាក់ប្រាប់សិស្សថា ពួកគេត្រូវតែជ្រើសរើសទីកន្លែងមួយដែលពួកគេចង់និយាយ ហើយចែករំលែកព័ត៌មានពីកន្លែងនោះជាមួយអ្នកដទៃ។ ពួកគេមិនគួរជ្រើសរើសយកព័ត៌មានអ្វីដែលខ្លួនមិនចូលចិត្ត ឬមិនដឹងច្បាស់មកសរសេរនោះទេ។



**ឧបសម្ព័ន្ធទី ៦៖ ការតែងកំណាព្យ**

1. កំណាព្យ ហៃគូ (Haiku)

វត្ថុបំណង ៖ ឱ្យសិស្សរៀនសរសេរកំណាព្យបែបជប៉ុន មានឈ្មោះថា ហៃគូ។

សម្ភារៈ ៖ ក្រដាស និងខ្មៅដៃ

ពេលវេលា ៖ ១ម៉ោង

ដំណើរការ ៖ ពន្យល់សិស្សថាកំណាព្យ ហៃគូ គឺជាទម្រង់មួយនៃកំណាព្យភាសាជប៉ុន។ ជាញឹកញាប់ វារៀបរាប់អំពីធម្មជាតិ និងវត្ថុទាំងឡាយនៃធម្មជាតិនៅក្នុងចក្រវាឡនេះ។

ទម្រង់កំណាព្យ ហៃគូ មានដូចខាងក្រោម៖

បន្ទាត់ទី 1៖ 5 ព្យាង្គ

បន្ទាត់ទី 2៖ 7 ព្យាង្គ

បន្ទាត់ទី 3៖ 5 ព្យាង្គ

| **របៀបចាប់ផ្តើម** |
| --- |
| បំផុសគំនិតរកពាក្យទាក់ទងនឹងធម្មជាតិ៖ ឧ. ភ្លៀង ពពក ខ្យល់រំភើយៗ |
| ជ្រើសរើសពាក្យដែលអ្នកចូលចិត្តពីតារាងបំផុសគំនិត |
| រាប់ចំនួនព្យាង្គ (វគ្គ) នៃពាក្យ |
| ដាក់ពាក្យទាំងនោះ ដូចក្នុងទម្រង់ខាងលើ |
| គូររូបភាពដែលសមនឹងកំណាព្យ ហៃគូ របស់អ្នក |

ចំណងជើង________________________________

បន្ទាត់ទី 1 ________________________________________________________________

បន្ទាត់ទី 2 ________________________________________________________________

បន្ទាត់ទី 3 ________________________________________________________________

## ២. កំណាព្យ ស៊ីនឃ្វីន (Cinquain)

វត្ថុបំណង ៖ ឱ្យសិស្សរៀនសរសេរកំណាព្យ**ស៊ីនឃ្វីន**។

សម្ភារៈ ៖ ថតចម្លងគំរូឧទាហរណ៍កំណាព្យ (ជម្រើស)

ពេលវេលា ៖ ១ ម៉ោង

ដំណើរការ ៖ ពន្យល់សិស្សថា **ស៊ីនឃ្វីន** គឺជាកំណាព្យមានរាងដូចគ្រាប់ពេជ្រ មាន៥ បន្ទាត់។

គំរូកំណាព្យ **ស៊ីនឃ្វីន**

| | |
| --- | --- |
| **សង្គ្រាម**<br>និពន្ធដោយ ពិសី<br><br>សង្គ្រាម<br>ដែលមានទុក្ខ ដែលបំផ្លិចបំផ្លាញ<br>ការសម្លាប់រង្គាល ការរងរបួស ការធ្វើឱ្យវិនាស<br>អំពើសម្លាប់ផ្តាច់ផ្តិលជីវិត<br>ចម្បាំង | **War**<br>by Pisey<br><br>War<br>Sad, destructive<br>Killing, injuring, destroying<br>A thing that kills life.<br>Terminator |

1. ឱ្យសិស្សធ្វើការក្រុមតូចពី ៣ ទៅ ៥នាក់។ ក្រុមនីមួយៗមានកំណាព្យគំរូមួយ កិច្ចការត្រូវបំពេញដូចតទៅ៖
   ក) កំណត់រចនាសម្ព័ន្ធ/ទម្រង់កំណាព្យ (តើថ្នាក់ពាក្យអ្វីនៅបន្ទាត់នីមួយៗ)
   ខ) រាយការណ៍ដោយផ្ទាល់មាត់ដល់សិស្សនៅក្នុងថ្នាក់ អំពីអារម្មណ៍/ការលើកដាក់សំឡេងកំណាព្យ
   គ) ឆ្លើយសំណួរ៖ តើបន្ទាត់ទីមួយមានទំនាក់ទំនងអ្វីជាមួយនឹងបន្ទាត់ចុងក្រោយ?
2. ទម្រង់រចនាសម្ព័ន្ធត្រូវសរសេរនៅលើក្តារខៀន ឬផ្ទាំងបញ្ចាំងស្លាយ ឬតាមរយៈសន្លឹកឯកសារដែលបានចែក

ឧទាហរណ៍

បន្ទាត់ទី ១៖ សង្គ្រាម (នាម ក-១)

បន្ទាត់ទី ២៖ ទុក្ខព្រួយ, វិនាស (គុណនាម ២ ដែលមានន័យទំនាក់ទំនងគ្នា)

បន្ទាត់ទី ៣៖ ការសម្លាប់រង្គាល , ការរងរបួស , ការបំផ្លិចបំផ្លាញ (នាមសព្ទដែលក្លាយមកពីកិរិយាសព្ទដែលប្រើសម្រាប់ពិពណ៌នាចំនួន ៣)

បន្ទាត់ទី ៤៖ អំពើសម្លាប់ផ្ដាច់ផ្តិលជីវិត (ឈ្លះមួយមានន័យពេញលេញ)

បន្ទាត់ទី ៥៖ ចម្បាំង (នាម ខ-១ ជាវេវចនៈសព្ទនឹងនាម ក)

3. ដឹកនាំសិស្សពិភាក្សា ត្រួតពិនិត្យមើលរចនាសម្ព័ន្ធកំណាព្យ ការអង្កេតផ្សេងៗទាក់ទងនឹងវេវចនៈសព្ទ ថ្នាក់ពាក្យតាមបន្ទាត់នីមួយៗ ពាក្យ/ការលើកដាក់សំឡេងបង្ហាញអារម្មណ៍។ល។
4. បន្ទាប់មកក្រុមនីមួយៗ "**ធ្វើសកម្មភាពបំផុសគំនិត**" រកពាក្យវេវចនៈសព្ទដែលគូនឹងគ្នាឱ្យបានច្រើនតាមដែលអាចរកបាន។ គ្រូដឹកនាំក្លឹបសរសេរពាក្យគូទាំងនោះនៅលើក្តារខៀន ឬផ្ទាំងបញ្ចាំងស្លាយ (ឧ. រិស្សមកាល-ថ្ងៃឈប់សម្រាក ហូប-ស៊ី សិល្បករ-អ្នកសម្តែង ...)។ សិស្សអាចប្រើវចនានុក្រមដើម្បីស្វែងរកវេវចនៈសព្ទទាំងនេះបាន។
5. សិស្ស និងគ្រូដឹកនាំជ្រើសរើសប្រធានបទមួយ ដែលបានពីសកម្មភាពបំផុសគំនិត ហើយតែងកំណាព្យ **ស៊ីនឃ្វីន** រួមគ្នានៅលើក្តារខៀន។ ជម្រើស៖ ចម្លងកំណាព្យ ហើយបន្ថែមទៅលើកម្រងកំណាព្យ ដែលបានកំពុងរៀបចំ ឬបោះពុម្ពក្នុងក្លឹបព្រឹត្តិបត្រ ឬដាក់តាំងលើក្តារខៀនព័ត៌មានក្លឹប។
6. សិស្សធ្វើការជាបុគ្គលប្រើទម្រង់ខាងក្រោម ដើម្បីតែងកំណាព្យ**ស៊ីនឃ្វីន** មួយ ឬច្រើន តាមមុខវិជ្ជាដែលពួកគេជ្រើសរើស។

## គំរូកំណាព្យប្រើនៅក្នុងថ្នាក់

| **ទន្លេ** | **River** |
|---|---|
| និពន្ធដោយ រដ្ឋា | by Ratha |
| ទន្លេ | River |
| ថ្លាយង់ ដ៏អស្ចារ្យ | Clear, wonderful |
| ការបោកបក់ ការក្តួច ការហូរ | Slapping, whirling, flowing |
| ទន្លេត្រជាក់ក្រៃ។ | The river is cold. |
| ទឹក | Water |

| **ធម្មជាតិ** | **Nature** |
|---|---|
| និពន្ធដោយ គង់យូ | by Kongyu |
| ធម្មជាតិ | Nature |
| ស្រស់ស្អាត បរិសុទ្ធ | Beautiful, pure |
| ការសមាធិ ការសប្បាយ ការបន្ធូរអារម្មណ៍ | Meditating, enjoying, relaxing |
| ធម្មជាតិនាំមកនូវសុខភាព។ | Nature is healthy. |
| រីករាយ | Fun |

| **សត្វព្រាប** | **Dove** |
|---|---|
| និពន្ធដោយ ចាន់នី | by Channy |
| ព្រាប | Dove |
| សកម្ម មានសេរីភាព | Active, free |
| ការហោះហើរ ការទំ ការស្រែក | Flying, sitting, crying |
| ព្រាបតំណាងសេរីភាព។ | A dove is free. |
| បក្សី | Bird |

| **អន្ទង់** | **Eel** |
|---|---|
| និពន្ធដោយ ស៊ីណាក់ | by Sinak |
| អន្ទង់ | Eel |
| រអិល វែង | Greasy, long |
| ការបត់បែន ការហែល ការផ្លាស់ទី | Winding, swimming, moving |
| អន្ទង់មានលក្ខណចម្លែក | An eel is strange. |
| ត្រី | Fish |

ចូរតែងកំណាព្យខ្លួនឯងដោយប្រើវាក្យស័ព្ទ/ប្រធានបទសាមញ្ញ/ស្មុគស្មាញ សមស្របទៅនឹងសកម្មភាពទៅតាមកម្រិតសមត្ថភាពសិស្សរបស់អ្នក

**គំរូកំណាព្យ**

ចំណងជើងកំណាព្យ

ឈ្មោះអ្នកនិពន្ធ

______________

______________, ____________

________________, _______________, ________________

_____________________________ .

______________

## ៣. តែងកំណាព្យដោយប្រើចំណងជើងកាសែត

វត្ថុបំណង ៖ លើកទឹកចិត្តសិស្សឱ្យស្វែងរកការបំផុសគំនិតពីប្រភពផ្សេងៗ

សម្ភារៈ ៖ កាសែត កន្ត្រៃ ការបិត

ពេលវេលា ៖ ១ម៉ោង

ដំណើរការ ៖

1. ឱ្យសិស្សធ្វើការជាបុគ្គល ជាគូ ឬជាក្រុម។
2. សូមប្រើប្រាស់អត្ថបទកាសែតដែលគ្រូផ្តល់ឱ្យ សិស្សត្រូវអានចំណងជើងកាសែតទាំងនោះ។ តើពួកគេរកឃើញគំនិត ឬប្រធានបទណាមួយទេ នៅក្នុងចំណោមចំណងជើងកាសែតទាំងអស់នោះ? ឧ. នយោបាយ ឧក្រិដ្ឋកម្ម ស្នេហា គ្រោះធម្មជាតិ បរិស្ថាន។ល។ ចំណងជើងទាំងនេះអាចប្រើដើម្បីបញ្ចូលន័យរួមគ្នាដើម្បីបង្កើតជាឃ្លាមួយ ដែលកើតឡើងនៅក្នុងពិភពលោកសព្វថ្ងៃ។
3. សិស្សជ្រើសរើសប្រធានបទ ឬគំនិតមួយ។
4. សិស្សជ្រើសរើសចំណងជើងកាសែតចំនួន ១០ ទៅ ១៥ ចំណងជើង។
5. សិស្សរៀបចំចំណងជើងតាមលំដាប់លំដោយបង្កើតឱ្យមានន័យ ឬឈ្មោះពេញលេញមួយ។ សិស្សអាចប្រើចំណងជើងទាំងអស់ដែលពួកគេបានជ្រើសរើស ឬគ្រាន់តែយកចំណងជើងខ្លះមកប្រើតែប៉ុណ្ណោះ។ ពួកគេអាចបញ្ចូលគំនិតផ្សេងទៀតដែលគេរកបាន។
6. សិស្សសរសេរឬកាត់ចំណងជើងបិទនៅលើផ្ទាំងធំមួយ។
   អត្ថបទនៅលើសន្លឹកក្រដាស ឬកាត់ជាបំណែកហើយបិតភ្ជាប់គ្នា។ បន្ថែមសញ្ញាវណ្ណយុត្តនៅចុងបញ្ចប់នៃបន្ទាត់នីមួយៗដែលអ្នកគិតថាត្រឹមត្រូវ ដូចជា សញ្ញាខណ្ឌ សញ្ញាក្បៀស សញ្ញាសួរ ជាដើម។
7. ប្រសិនបើសិស្សច្រើនជាងម្នាក់ចង់កាត់បន្ថយអត្ថបទចំណងជើងកាសែត សិស្សម្នាក់ក្នុងចំណោមពួកគេត្រូវសរសេរចូលនូវចំណងជើងទាំងនោះដាក់នៅលើក្រដាសសិន។
8. ប្រសិនបើពួកគេកាត់ហើយបិតភ្ជាប់គ្នារួច ពួកគេអាចបន្ថែមរូបថត គំនូរ ឬបំណាកស្រាយផ្សេងៗពីកាសែត ឬតាមការច្នៃប្រឌិតរបស់ពួកគេ។
9. ដាក់ចំណងជើងឱ្យការបង្កើតរបស់ពួកគេ ហើយចែកឱ្យសមាជិកក្លឹបមើលទាំងអស់គ្នា។

## ៤. កំណាព្យពៃសុនា (Persona)

វត្ថុបំណង ៖ ឱ្យសិស្សកាន់តែស្គាល់គ្នាទៅវិញទៅមកកាន់តែច្បាស់

សម្ភារៈ ៖ ក្រដាស និងខ្មៅដៃ

ពេលវេលា ៖ ១ម៉ោង

ដំណើរការ ៖ កំណាព្យពៃសុនា គឺជាកំណាព្យដែលមាន៨ជួរ ផ្តោតលើលក្ខណៈជីវសាស្ត្របែបធម្មជាតិ។ ដែលបានកែសម្រួលពីគំនិតរបស់លោក June B. White បច្ចុប្បន្នធ្វើការនៅមូលនិធីហ្គ្រេសប៉ូលីត (The Grace Polite Foundation) នៃទីក្រុងឃ្វីតតូ ប្រទេសអេក្វាឌ័រ។

គំរូកំណាព្យពៃសុនា

| |
|---|
| លោកស្រី មីលីហ្សា<br>ដែលជម្រុញទឹកចិត្ត, ដែលមានថាមពល ដែលចេះទំនុកបំរុង ដែលចេះថែរក្សា<br>កូនស្រីរបស់ជាអាណា<br>ដែលចូលចិត្តការហែលទឹក ការអានសៀវភៅ និងស្តាប់ចំរៀង<br>ដែលខ្លាចត្រីឆ្លាម សត្វពស់ និងដើរនៅកន្លែងងងឹតម្នាក់ឯង<br>ដែលចង់ទៅលេងប្រទេសអាហ្វ្រិក ចាម៉ៃកា និងមហាវិទ្យាល័យដែលប្អូនប្រុសរបស់នាងបានរៀនចប់<br>គឺជាមនុស្សម្នាក់រស់នៅលើភពផែនដី<br>ជាអ្នករស់នៅទីក្រុង ក្រាកូវ នៃប្រទេសប៉ូឡូញ |

## សកម្មភាពត្រៀម

កំណាព្យពៃសុនាជាកិច្ចការសំណេរល្អមួយនៅក្នុងថ្នាក់នៅពេលចាប់ផ្តើមត្រីមាសដំបូង នៅពេលដែលសិស្សជួបស្វាគមន៍គ្នា និងការស្គាល់គ្នា។ សិស្សយករូបថត ឬប្រមូលរូបភាពពីទស្សនាវដ្តី ឬគូររូបភាពដោយខ្លួនឯង ដែលរបស់ទាំងនេះនឹងក្លាយជាមូលដ្ឋានក្នុងការនិពន្ធកំណាព្យរបស់ពួកគេ។

**ការណែនាំ**

1. ធ្វើការជាក្រុមតូច ឬសិស្សក្នុងថ្នាក់ទាំងអស់ ហើយមើលទៅគំរូកំណាព្យអំពី "**ខេត**" ហើយពិភាក្សាពីការតែងកំណាព្យជា ៨ ជួរ។ តើថ្នាក់ពាក្យ ឬក្រុមនៃពាក្យតំណាងឱ្យអ្វីនៅក្នុងបន្ទាត់នីមួយៗ?
2. ដោយប្រើគំរូ (ខាងក្រោម) សិស្សធ្វើការងារជាបុគ្គល ហើយសរសេរអំពីខ្លួនពួកគេ ឬធ្វើការជាគូរ និងសរសេរពីដៃគូរបស់ពួកគេ។

**គំរូវិភាគលើកំណាព្យ Persona**

<u>**បន្ទាត់ទី ១៖**</u> ខេត ជាឈ្មោះ/ឈ្មោះហៅក្រៅរបស់មនុស្សម្នាក់នៅក្នុងកំណាព្យ

<u>**បន្ទាត់ទី ២៖**</u> ខ្ពស់ ស្វាហាប់ សប្បាយ ឆ្លាត ជាគុណនាម ៤ ដែលរៀបរាប់ពីបុគ្គលិកលក្ខណៈរបស់មនុស្ស

<u>**បន្ទាត់ទី ៣៖**</u> ម្តាយរបស់ដេនី (Danny) ជារូបមន្ត X នៃ Y ពណ៌នាពីទំនាក់ទំនងរវាងមនុស្សម្នាក់ទៅនឹងមនុស្សម្នាក់ទៀត)

<u>**បន្ទាត់ទី ៤៖**</u> ដែលស្រលាញ់តន្ត្រី សៀវភៅ និងខ្យល់អាកាសបរិសុទ្ធ ជាវត្ថុទាំង ៣ យ៉ាងដែលគាត់ស្រលាញ់

<u>**បន្ទាត់ទី៥៖**</u> ដែលខ្លាចលោកប្រធានាធិបតី Bush សត្វពីងពាង និងឋានៈ ជាវត្ថុទាំង ៣ ដែលធ្វើឱ្យគាត់ខ្លាច

<u>**បន្ទាត់ទី៦៖**</u> ដែលចង់ឃើញ អាមេរិកឡាទីន ការបញ្ចប់ភាពក្រីក្រ និងរដូវក្តៅ ជាវត្ថុទាំង ៣ ដែលគាត់ចង់ឃើញ

<u>**បន្ទាត់ទី៧៖**</u> រស់នៅឯ... ជាអ្នករស់នៅនៃ + ទីកន្លែង/ពេលវេលា/ទស្សនៈ

<u>**បន្ទាត់ទី៨៖**</u> ថមសុន (Thompson) ជាត្រកូលរបស់បុគ្គលនៅក្នុងកំណាព្យ

គំរូកំណាព្យ
(តម្រឹមស្តាំ កណ្តាល ឬឆ្វេង តាមការចូលចិត្តខុសៗគ្នា)
ចំណងជើងកំណាព្យ
ឈ្មោះអ្នកនិពន្ធ

__________________ …..(ឈ្មោះ)
____________, ____________, _____________, ____________
____________ នៃ ____________
ដែលស្រលាញ់ ____________, ____________ និង ____________
ដែលខ្លាច ____________, ____________ និង ____________
ដែលចង់ឃើញ ____________, ____________ និង ____________
រស់នៅឯ ____________
…________________. (ត្រកូល)

**សកម្មភាពតាមដាន**
សិស្សបញ្ចប់ការបិតរូបភាពរបស់ពួកគេ រួមទាំងកំណាព្យផងដែរ។ កំណាព្យបែបពៃសុនា បង្កើតជាផ្ទាំងរូបភាពលើជញ្ជាំងល្អ ឬជាកម្រងស្នាដៃសម្រាប់តាំងក្នុងថ្នាក់ ទាំងអស់នេះជាវិធីល្អមួយជួយសិស្សស្វែងយល់ពីមិត្តភក្តិរបស់ពួកគេកាន់តែច្បាស់ ហើយប្រើប្រាស់ជាការចាប់ផ្តើមការសន្ទនាដែលគួរឱ្យចាប់អារម្មណ៍។



**ឧបសម្ព័ន្ធទី៧៖ សៀវភៅទិនានុប្បវត្តិ**



- បង្កើតទិនានុប្បវត្តិទៅជាកំណត់ហេតុការអាន – ឱ្យសិស្សបង្កើតសំណួរពីការអាន កត់ត្រាពីអារម្មណ៍របស់ពួកគេ ឬប្រតិកម្មចំពោះការជ្រើសរើស ឆ្លើយសំណួរដែលគ្រូដឹកនាំបានដាក់ឱ្យ។ល។
- សួរសំណួរគួរឱ្យចាប់អារម្មណ៍ពីព្រឹត្តការណ៍បច្ចុប្បន្ន ជីវិតនៅក្នុងសហគមន៍របស់ពួកគេ ឬជីវិតសាមញ្ញឱ្យសិស្សឆ្លើយ។ សូមឱ្យសិស្សបានគិតដោយការពិចារណា។
- ឱ្យសិស្សសរសេរត្រឡប់មករកអ្នកវិញ ឬសរសេរឱ្យគ្នាទៅវិញទៅមក នៅពេលពួកគេទទួលបានការផ្តល់មតិយោបល់កែសម្រួលពីការងាររបស់គេ។
- ឱ្យសិស្សមានភាពសប្បាយរីករាយតាមរយៈការប្រៀបធៀប។ ឱ្យសិស្សបំពេញល្បះដូចខាងក្រោម៖ "ជីវិតប្រៀបដូចជា ________, ព្រោះ __________."
- លើកទឹកចិត្តសិស្សឱ្យសរសេរកំណាព្យ។

**ឧបសម្ព័ន្ធទី ៨៖ ការអានសំណួរពិភាក្សាយល់ដឹង**

សំណួរទូទៅខាងក្រោម អាចត្រូវបានដាក់បញ្ចូលទៅក្នុងរឿង ឬអត្ថបទប្រលោមលោកខ្លីៗ ហើយវាអាចឱ្យអ្នកចាប់ផ្ដើមបង្កើតសំនួរពិភាក្សាបានយ៉ាងល្អសម្រាប់ការងារដែលបានដាក់ឱ្យធ្វើ។

- តើអ្វីជាលក្ខណដាច់ដោយឡែកពីគេក្នុងការសរសេររឿង ឬសៀវភៅ ហើយតើលក្ខណនោះធ្វើឱ្យរឿងប្រសើរឡើងដូចម្ដេច?
- តើគំនិតសំខាន់អ្វីដែលអ្នកនិពន្ធចង់បញ្ជាក់នៅក្នុងសាច់រឿងប្រលោមលោក? តើអ្នកគិតថា អ្នកនិពន្ធចង់ឱ្យអ្នកអានពីអ្វី?
- តើតួអង្គទំនងជាតួអង្គពិត និងជឿជាក់បានទេ? តើអ្នកអាចភ្ជាប់ទៅនឹងស្ថានភាពរបស់តួអង្គក្នុងរឿងបានទេ? តើរឿងនោះរំលឹកអ្នកពីខ្លួនអ្នក ឬអ្នកដទៃដែលអ្នកស្គាល់កម្រិតណា?
- តើតួអង្គបានផ្លាស់ប្ដូរយ៉ាងដូចម្ដេចនៅក្នុងរឿង? តើព្រឹត្តការណ៍អ្វីដែលផ្ដើមឱ្យមានការផ្លាស់ប្ដូរទាំងនោះ?
- តើព្រឹត្តការណ៍នៅក្នុងសៀវភៅទាំងនោះបានបង្ហាញកស្តុតាងអ្វីខ្លះអំពីទស្សនៈរបស់អ្នកនិពន្ធ?
- តើផ្នែកខ្លះនៃសៀវភៅធ្វើឱ្យអ្នកមិនយល់ស្របដែរឬទេ? ប្រសិនបើមាន ហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ? តើរឿងនេះបានធ្វើឱ្យទទួលចំណេះដឹងថ្មីៗ ដែលអ្នកមិនធ្លាប់គិតដល់ស្ដីពីទិដ្ឋិភាពជីវិតរស់នៅរបស់អ្នកឬទេ?
- តើអ្វីដែលធ្វើឱ្យអ្នកសប្បាយរីករាយពីការអានរឿងឬសៀវភៅនេះទេ?
- តើអ្នកបានអានពីអ្វីនៅក្នុងរឿងឬសៀវភៅដែលស្រដៀងសាច់រឿងនេះទេ?
- តើគំនិតសំខាន់ក្នុងរឿងឬសៀវភៅនោះមានអ្វីខ្លះ?
- តើអ្នកគិតថាអ្នកនិពន្ធព្យាយាមបង្ហាញអ្វីនៅក្នុងរឿងឬរឿងប្រលោមលោក?
- តើនរណាជាតួអង្គដែលអ្នកពេញចិត្ត? តើអ្នកបានកោតសរសើរអ្វីខ្លះពីតួអង្គនោះ?
- ចូរពិចារណាលើតួអង្គសំខាន់ តើតួអង្គនោះជឿលើអ្វី? តើតួអង្គនោះចង់បានអ្វី?
- នៅចុងបញ្ចប់របស់រឿងឬសៀវភៅ តើអ្នកមានសង្ឃឹមចំពោះតួអង្គឬទេ?
- តើអ្វីជាចំណុចខ្លាំងជាងគេនៅក្នុងរឿង ឬសៀវភៅនេះ៖ ខ្សែសាច់រឿង ឬការអភិវឌ្ឍតួអង្គក្នុងរឿង? ហេតុអ្វី? តើអ្នកគិតថា វាជាចេតនារបស់អ្នកនិពន្ធឬទេ?
- តើអ្នកធ្លាប់បានជួបប្រទះនឹងបញ្ហាអ្វីមួយដែលប្រហាក់ប្រហែលនឹងសាច់រឿងឬសៀវភៅនោះឬទេ?
- តើមានអ្វីខ្លះអំពីរឿង/សៀវភៅនេះ?
- តើអ្នកមានការព្រួយបារម្ភយ៉ាងណាចំពោះរឿង ឬសៀវភៅនេះ?
- តើអ្វីជាទំនាក់ទំនងសំខាន់ជាងគេបំផុតនៅក្នុងរឿង ឬសៀវភៅនេះ?
- តើអ្វីដែលធ្វើឱ្យតួអង្គបន្ទាប់បន្សំមានការចង់ចាំ?
- តើផ្នែកសាច់រឿងណាខ្លះដែលមានលក្ខណៈអប់រំល្អបំផុត?
- តើព្រឹត្តការណ៍នៅក្នុងរឿង ឬសៀវភៅមានទំនាក់ទំនងទៅនឹងជីវិតពិតរបស់អ្នកឬទេ?
- តើគិតយ៉ាងដូម្ដេចចំពោះវិធីសរសេររបស់អ្នកនិពន្ធ?
- តើរឿងនោះវាអាចគួរឱ្យជឿជាក់បានទេ? តួអង្គគួរឱ្យជឿទុកចិត្តបានឬទេ?
- តើអ្នកឃើញកំហុសឬគុណវនៅក្នុងសៀវភៅនេះទេ?